# បន្តោងមង្គលបង្ការការ ឆបោករបស់ក្រុមហ៊ុន 「ស៊ីងអាន់」

## ដើម្បីលោក(អ្នក)រួមដំណើរប្រឆាំងការពារល្បិច ឆបោក




TOKIO MARINE NEWA 新安東京海上產險

# ការបង្ការល្បិចក្លែងបន្លំជា「ភ្នាក់ងារជំនួស」

「ធានារ៉ាប់រងបោកប្រាស់」 ជាទូទៅគេតែងនិយាយថា គេអាចឆ្លងកាត់បណ្ដាញពិសេសឬ ក៏គេក្លែងបន្លំជាបុគ្គលិកសុខុមារភាពសង្គម ដើម្បីជួយស្វែងរកសំណងធានារ៉ាប់រងជំនួសម្ចាស់ឈរឈ្មោះ ដើម្បីទាមទារសំណងបានកាន់តែខ្ពស់មកជូនម្ចាស់ធានារ៉ាប់រង។ បន្ទាប់មកគេនឹងទាមទារថ្លៃសេវាកម្មយ៉ាងខ្ពស់មកវិញ ឬក៏បោកយកប្រាក់សំណងតែម្ដង។

## ចំនេះដឹងទាក់ទិនធានារ៉ាប់រង

ជាការពិត ការស្នើសុំសំណងធានារ៉ាប់មិនពិបាកទេ គ្រាន់តែលោក (អ្នក)គ្រប់លក្ខខណ្ឌ និងត្រៀមឯកសារទាំងនោះ ដើម្បីធ្វើការដាក់ស្នើសុំទៅក្រុមហ៊ុនធានារ៉ាប់រងដើម នឹងទទួលបានសំណងដូចក្នុងលក្ខខណ្ឌគោលការណ៍ធានារ៉ាប់រងនោះ។ ក្រៅពីនេះនៅក្នុងវេបសាយរបស់ក្រុមហ៊ុនធានារ៉ាប់រងក៏មានផ្ដល់ជូននូវពត៏មានទាក់ទិនការស្នើសុំសំណងពីក្រុមហ៊ុនធានារ៉ាប់រងផងដែរ។



# ផ្ញើឯកសារបញ្ជាប់ 「ក្រុមហ៊ុនក្លែងក្លាយ」

ក្រុមឆបោកតែងទំលាប់ប្រើល្បិច ក្លែងក្លាយ ដូចជា: ផ្ញើសារឲ្យបង់ប្រាក់, ផ្ញើសារឲ្យបន្តកុងត្រា ឬមានប្រូម៉ូសិនពិសេសជាដើម។ដើម្បីទាក់ទាញអតិថិជនបង់ប្រាក់តាមអនឡាញ ហេតុដូច្នេះហើយមុននឹងធ្វើសកម្មភាពអ្វីមួយតាមអនឡាញ ចាំបាច់ត្រូវតែធ្វើតេស្តសិន ជៀសវាងត្រូវបានពួកគេបំភាន់ភ្នែកយើងបាន។

## ចំនេះដឹងទាក់ទិនធានារ៉ាប់រង

ការប្រើប្រាស់បណ្តាញដោយសុវត្ថិភាព។ ដើម្បីប្រាកដថានោះជាវេបសាយត្រឹមត្រូវ សូមកុំចុចចូលសារដែលបានភ្ជាប់វេបសាយមិនច្បាស់លាស់។ ពេលបានចុចភ្ជាប់វេបសាយនោះហើយ ប្រសិនបើមានការសង្ស័យអ្វីមួយ សូមកុំខលទៅបញ្ជាក់ពីក្រុមហ៊ុនធានារ៉ាប់រងនោះឲ្យសោះ។



# ការប្រុងប្រយ័ត្ន
# 「ឯកសារធានារ៉ាប់រងក្លែងក្លាយ」

ក្រុមឆបោកអាចនឹងមានល្បិច ហ្វូតូឯកសារធានារ៉ាប់ ឬឯកសារបញ្ជាក់បង់ប្រាក់ ឬ វិក័យប័ត្រជាដើម ដើម្បីបោកបញ្ឆោតសាធារណជន។ ក្រៅពីនេះទៅទៀត ប្រសិនអ្នកទិញនូវធានារ៉ាប់រងក្រៅប្រពន្ធ័របស់ បរទេស ពេលមានជម្លោះកើតឡើង អ្នកទិញអាចនឹងមិនមានសំណងមកវិញផង។

## ចំនេះដឹងទាក់ទិនធានារ៉ាប់រង

ធានារ៉ាប់រងក្រៅប្រពន្ធ័របស់ បរទេស គឺសំដៅធានារ៉ាប់រងដែលមិនបានទទួលស្គាល់ពីអង្គភាពស្ថាប័នរបស់តៃវ៉ាន់ទេ។ ដោយសារ ការអនុវត្តច្បាប់នៅតៃវ៉ាន់ មិនអាចគ្រប់គ្រងរចនាសម្ព័ន្ធធានារ៉ាប់រងបរទេសដែលលក់នៅតៃវ៉ាន់បានឡើយ ហេតុដូច្នេះអ្នកទិញ ត្រូវទទួលខុសត្រូវហានិភ័យដោយខ្លួនឯង។ ជាយោបល់ : សូមសាធារណជនទាំងឡាយទិញនូវឯកតាធានារ៉ាប់ដែលជាក្រុមហ៊ុនស្របច្បាប់នៅតៃវ៉ាន់។



# ការបដិសេធក្នុង
# 「ករណីសំណងក្លែងក្លាយ」

គ្រោះថ្នាក់ចរាចរណ៍មិនពិត ការបាត់បង់សមត្ថភាពរាងកាយមិនពិត គ្រោះថ្នាក់ថែដន្សមិនពិតឬ បង្កើតរោគជំងឺមិនពិត ទាំងអស់នេះសុទ្ធតែ「ល្បិចក្រុមឆបោក」ឧស្សាហ៍ប្រើជាញឹកញាប់! សូមសាធារណជនកុំសហការ ទាំងដែលដឹងថាវាមានចំណុចសង្ស័យ ដើម្បីជៀសវាងទីបំផុតយកលុយមិនបាន ថែមទាំងក្លាយជាសត្វពាពៃទទួលទោសជំនួសក្រុមឆបោកទៀត។

## ចំនេះដឹងទាក់ទិនធានារ៉ាប់រង

ប្រសិនបើលោក(អ្នក)ប្រើឯកសារមិនពិតដើម្បីស្នើសុំសំណង នោះនឹងក្លាយជា ឧក្រិដ្ឋជន ប្រើឯកសាក្លែងបន្លំ មិនត្រឹមតែមិនទទួលបានសំណងប៉ុណ្ណោះទេ ក្រុមហ៊ុនធានារ៉ាប់រងនឹងទាមទារសំណងខូចខាតតាមផ្លូវច្បាប់មកវិញ។



# 「កុំ」៥បង្ការ ឆបោក

## 「កុំ」ចុចចូលវេបសាយដែលមិនច្បាស់ :

សូមកុំចុចចូលវេបសាយដែលមានភ្ជាប់មកនូវប្រភពមិន
ច្បាស់លាស់ និងវេបសាយទម្រង់មួយទំព័រ។

## 「កុំ」ផ្តល់នូវឯកសារផ្ទាល់ខ្លួន:

ក្រៅពីវេបសាយពិតរបស់ក្រុមហ៊ុនយើងខ្ញុំ សូមកុំផ្តល់ឯកសារផ្ទាល់
ខ្លួនទៅកាន់វេបសាយផ្សេងៗទៀត។

## 「កុំ」ស្តាប់ហើយជឿលើប្រភពពិសេស :

ប្រសិនបើចង់ស្នើសុំសំណងពីធានារ៉ាប់រង សូមកុំស្តាប់យោបល់បុគ្គល
ដែលមានប្រភពមិនច្បាស់លាស់ អាចនឹងចូលអន្ទាក់បោកបញ្ឆោត
របស់ពួកគេ។

## 「កុំ」ស៊ីញ៉េឈ្មោះឲ្យឯកសារដែលមានប្រភពមិនច្បាស់លាស់:

បើទោះបីឯកសារមិនស្របច្បាស់របស់ក្រុមហ៊ុនធានារ៉ាប់រងណាមួយក៏
ដោយ ក៏មិនត្រូវស៊ីញ៉េឈ្មោះដែរ

## 「កុំ」ងាយជឿលើពត៌មានគួរសង្ស័យ:

ពេលចាប់អារម្មណ៍នឹងឬ មានអារម្មណ៍សង្ស័យ
លើសារ ឬពត៌មានទាំងឡាយ ប្រសិនមានការ
សង្ស័យហើយឆាប់តេលេខ 165 បណ្តាញបង្ការនិង
ផ្តល់ពត៌មានទាក់ទិនក្រុមឆបោក។



# បង្ការឆបោក៤「ចាំបាច់」

## 「ចាំបាច់」ត្រូវស្វាហាប់ស៊ើបរកវត្ថុបញ្ជាក់ការពិត:

មុនលោក(អ្នក)ទិញនូវធានារ៉ាប់រង ចាំបាច់ត្រូវទាមទារឲ្យភាគីបង្ហាញនូវតួនាទីការងារនិងស្ថាប័នភ្នាក់ងារថាពិតឬទេ។

## 「ចាំបាច់」ត្រូវក្រើនរំលឹកបន្ថែម:

ទ្រឹស្ដីក្រុមឆបោក ឧស្សាហ៍ប្រើ និងបង្កើតវេបសាយមិនពិតបោកបញ្ឆោតសាធារណជនផ្ដល់ជូននូវក្រេឌីតខាត ឬលេខគណនីធនាគារជាដើម...យើងចាំបាច់ត្រូវប្រុងប្រយ័ត្នឲ្យបានខ្ពស់ ជៀសវាងធ្លាក់ក្នុងអន្ទាក់គេ។

## 「ចាំបាច់」ធ្វើការបញ្ជាក់បន្ថែម:

ប្រសិនបើចាប់អារម្មណ៍ថាភ្នាក់ងារធានារ៉ាប់រងមិនប្រក្រតី គួរតែស៊ើបសួរទៅកាន់ក្រុមហ៊ុនធានារ៉ាប់រងបញ្ជាក់ ដើម្បីរក្សានូវសិទ្ធិនិងសុវត្ថិភាពផ្ទាល់ខ្លួន។

## 「ចាំបាច់」ស្វែងយល់កាន់តែច្រើន:

អាចទៅស្ដាប់ពីវិធីបង្ការ ការឆបោកនិងល្បិចក្លែងបន្លំគ្រប់ប្រភេទ ដែលបកស្រាយជូនពីគណៈកម្មការត្រួតពិនិត្យហិរញ្ញវត្ថុ ! ដើម្បីបង្កើនសមត្ថភាពបង្ការខ្លួនពីក្រុមឆបោក ព្រមទាំងទទួលបានចំនេះដឹងទាក់ទិនការធានារ៉ាប់រងហិរញ្ញវត្ថុ។





# សៀវភៅណែនាំវិធីបង្ការ ឆបោកតាមអេឡិចត្រូនិច

**Calm Down** ដោះស្រាយដោយចិត្តត្រជាក់

**Check it out** ស្វែងរកឯកសារបញ្ជាក់ការពិតដោយល្អិតល្អន់

**Call out 165** ខលទៅកាន់បណ្ដាញស៊ើបសួរ 165

ប្រសិនបើមានស្ថានភាពគួរសង្ស័យកើតឡើង
សូមបង្កើនការស្វែងរកឯកសារបញ្ជាក់ និងប្រុងប្រយ័ត្ន
បន្ទាប់មកតែទៅសុំជំនួយពីបណ្ដាញបង្ការ ឆបោក 165

វេបសាយធានារ៉ាប់រងអចលនទ្រព្យ「ស៊ីងអាន់តុងជីនហៃសាំង」

ល្បែងប្រយុទ្ធប្រឆាំងនឹងបង្ការការឆបោក

新安東京海上產險 យកចិត្តទុកដាក់លោក(អ្នក)

អាស័យដ្ឋាន: ក្រុងតៃប៉ិ ខណ្ឌចុងសាន ណាន់ជីងតុងលូ ៣ ទណ្ឌ លេខ130 ជាន់ទី 8~13 ទូរស័ព្ទ: (02)8772-7777

បណ្ដាញសេវាកម្មនិងដាក់ពាក្យបណ្ដឹងដោយឥតគិតថ្លៃ

**0800-050-119**

វេបសាយស៊ើបរកព័ត៌មានដោយបើកចំហរ: https://www.tmnewa.com.tw

To Be a Good Company